**ឧបសម្ព័ន្ធ២៖ សេចក្តីណែនាំរបស់ការិយាល័យ OHCHR ស្តីពីជំងឺកូវីដ-១៩ និងជនជាតិភាគតិច (មេសា ២០២០)**

ចំពោះវិធីសាស្ត្រមូលដ្ឋានរបស់សិទ្ធិមនុស្ស គួរតែត្រូវបានអនុវត្តចំពោះមនុស្សទាំងអស់ដែលរងផលប៉ះពាល់ដោយវិបត្តិនេះ ហើយជាពិសេសគោលបំណងនៃលិខិតពីរទំព័រនេះ គឺដើម្បីធានាថារាល់ជនជាតិភាគតិចទាំងអស់ (ជាតិសាសន៍ ឬជនជាតិ ភាសា សាសនា) មិនត្រូវបានគេមើលរំលង ឬរើសអើងបន្ថែមទៀត ពីការទទួលបានសេវាទាំងឡាយដោយស្មើភាពគ្នា ឬក្លាយជាជនរងគ្រោះដោយអំពើហិង្សា ឬទម្រង់ណាមួយផ្សេងទៀត នៃការរំលោភសិទ្ធិមនុស្សក្នុងអំឡុងពេល ឬក្រោយពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ។

ខណៈពេលដែលកំពុងប្រឈមមុខនឹងវិបត្តិនៃជំងឺកូវីដ-១៩ រដ្ឋគួរគោរពច្បាប់សិទ្ធិមនុស្សអន្តរជាតិឲ្យបានពេញលេញ រាប់បញ្ចូលទាំង សិទ្ធិមនុស្សជនជាតិភាគតិច។ រដ្ឋគួរផ្តោតលើការដោះស្រាយស្ថានភាពបន្ទាន់បំផុតរបស់ពលរដ្ឋងាយរងគ្រោះក្នុងអំឡុងពេលមានវិបត្តិសុខភាព និងលើកកម្ពស់ការគោរពចំពោះភាពចម្រុះ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងការពារប្រយុទ្ធប្រឆាំងនឹងការរំលោភសិទ្ធិមនុស្ស ជាពិសេស អំពើហឹង្សា ការមិនអត់ឱន និងសន្ទរកថាដែលមានចរិកខឹងស្អប់ និងការផាត់ចេញពីសង្គម និងការរើសអើង រួមទាំង ការទទួលបានសេវាថៃទាំសុខភាព ការអប់រំ និងសេវាសង្គម។

រដ្ឋគួរតែផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងជំងឺកូវីដ-១៩ ក្នុងទម្រង់សមស្របសម្រាប់សហគមន៍ជនជាតិភាគតិចជាភាសា ដែលពួកគេអាចយល់បាន និយាយបាន និងស្របតាមវប្បធម៌របស់ពួកគេ រួមទាំងព័ត៌មានលម្អិត និងពន្យល់ពីវិធានការបង្ការ ក៏ដូចជា ស្ថានភាពសុខភាពដែលជាសក្តានុពល ដែលពួកគេអាចនឹងប្រឈម។ រដ្ឋគួរតែផ្សព្វផ្សាយព័ត៌មានបន្ថែមទៀត ដល់សហគមន៍ អំពីវិធានការរបស់អាជ្ញាធរសាធារណៈ ក៏ដូចជា ផែនការរបស់រាជរដ្ឋាភិបាល និងកត្តាផ្សេងទៀត ដែលរដ្ឋគួរតែអភិវឌ្ឍន៍លក្ខខណ្ឌសុខភាពទាក់ទងនឹងជំងឺកូវីដ-១៩។ សាធារណៈជន អាចស្វែងរកបាននូវព័ត៌មាន និងការទទួលបានព័ត៌ជាភាសាជនជាតិភាគតិច ក៏ដូចជា នៅក្នុងទម្រង់មួយ ដែលអាចដំណើរការបានសម្រាប់ជនជាតិភាគតិច រួមទាំង ការផ្សព្វផ្សាយទៅកាន់តំបន់ដែលមិនមានសេវាអ៊ីនធឺណេត។ គួរតែមានការដកបំរាមចេញពីទីតាំងដែលមានការហាមឃាត់សេវាអ៊ីនធឺណេត ដើម្បីធានាថា មនុស្សគ្រប់រូប រួមទាំងជនជាតិភាគតិចនៅក្នុងតំបន់ទាំងនោះទទួលបានព័ត៌មានស្មើៗគ្នា។ គួររាប់បញ្ចូលជនជាតិភាគតិច ក្នុងការចលនាព័ត៌មាន និងយុទ្ធនាការគាំទ្រ។

ជំងឺកូវីដ-១៩ គឺជាបញ្ហាប្រឈមដ៏ធំមួយសម្រាប់សង្គមទាំងមូល ដូចនេះ រដ្ឋាភិបាលត្រូវពង្រឹង និងចាត់វិធានការណ៍តឹងរឹងមួយចំនួន រួមបញ្ចូលទាំង ការរក្សាគម្លាតពីគ្នា ការសិក្សាពីផ្ទះ និងធានាបាននូវការទទួលបានទំនិញមូលដ្ឋាន និងមណ្ឌលថៃទាំសុខភាព និងលទ្ធភាពទទួលបានការព្យាបាលសុខភាព។ រដ្ឋគួរដាក់ចេញនូវវិធានការណ៍បន្ថែម ដើម្បីដោះស្រាយផលវិបាក ដែលកាន់តែអាក្រក់ទៅៗ នៃជំងឺកូវីដ-១៩ ចំពោះជនជាតិភាគតិច ដែលមានវិបត្តិសុខភាពដោយសារបញ្ហាសេដ្ឋកិច្ច និងសង្គម ដែលមិនបានត្រៀមទុកជាមុននៅក្នុងទីតាំង ឬតំបន់ដែលពួកគេរស់នៅ ឬត្រូវបានរឹតត្បិតសម្រាប់ការទទួលបានទំនិញ និងសេវាមូលដ្ឋាន ដោយសារការរើសអើងដោយផ្ទាល់ ឬដោយប្រយោលពីសំណាក់ស្ថាប័នរដ្ឋ។ ជនជាតិភាគតិចច្រើនតែរស់នៅក្នុងស្ថានភាពលំនៅដ្ឋានចង្អៀតណែន ធ្វើឲ្យកាន់តែពិបាកក្នុងការរក្សាគម្លាត និងការដាក់ខ្លួនឲ្យនៅដាច់ដោយឡែក។ ការប្រើប្រាស់ប្រព័ន្ធឌីជីថលនៅមានកម្រិត ហើយភាពខ្វះចន្លោះនៃការអប់រំរបស់ឪពុកម្តាយក៏អាចធ្វើឲ្យការសិក្សាពីផ្ទះមានភាពលំបាកជាងមុន ដែលទីបំផុត មិនគួរបង្កឲ្យមានការផាត់ចេញពីសង្គមឡើយ។ រដ្ឋត្រូវធានាថា សហគមន៍ជនជាតិភាគតិច អាចអនុវត្តវិធានការចាំបាច់ ដើម្បីការពារខ្លួនពួកគេ ដូចជា មានលំនៅឋានសមរម្យ ការទទួលបានទឹកស្អាត អាហារ និងប្រភពថាមពលផ្សេងៗ ដោយរួមបញ្ចូលទាំងអគ្គីសនីសម្រាប់ទទួលបានការអប់រំពីចំងាយតាមប្រព័ន្ធអ៊ីនធឺណេតផងដែរ។

រដ្ឋាភិបាលកំពុងប្រឈមមុខនឹងតម្រូវការធនធានដ៏ធំធេងនៅក្នុងវិបត្តិនេះ ហើយដែលត្រូវធ្វើឲ្យមានការពិបាកក្នុងការសម្រេចចិត្ត ប៉ុន្តែពួកគេ មិនគួរបំភ្លេចជនដែលងាយរងគ្រោះបំផុតឡើយ។ មិនត្រូវបដិសេធបុគ្គលណាមួយពីការ

ទទួលបានការថែរក្សាសុខភាពដោយសារតែភាពមាក់ងាយ ឬដោយសារតែពួកគេជាក្រុមជាក់លាក់ណាមួយ ដែលអាចនាំឲ្យពួកគេបាត់បង់ឱកាស។ បុគ្គលជនជាតិភាគតិច អាចត្រូវបានគេផាត់ចេញពីការថែរក្សាសុខភាព ដោយសារតែពួកគេខ្វះធនធាន ឬឯកសារផ្លូវការ ឬដោយសារការរើសអើង ឬការមាក់ងាយ។ រដ្ឋគួរធានាឲ្យបាននូវសិទ្ធិទទួលបានការថែទាំសុខភាពរបស់ជនជាតិភាគតិច រួមទាំងអ្នកដែលគ្មានធានារ៉ាប់រងសុខភាព ឬឯកសារបញ្ជាក់អត្តសញ្ញាណ។

ការប្រកាសអាសន្នដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ មិនគួរត្រូវបានប្រើជាមូលដ្ឋាន ដើម្បីកំណត់គោលដៅទៅលើក្រុមជាក់លាក់ ក្រុមជនជាតិភាគតិច ឬបុគ្គលណាមួយឡើយ។ វិធានការនានា មិនត្រូវពាក់ព័ន្ធនឹងការរើសអើងលើមូលដ្ឋាននៃពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ជំនឿ នយោបាយ ឬទស្សនៈផ្សេងទៀត ជាតិពិន្ទុ ដើមកំណើតសង្គម ជាតិសាសន៍ ទ្រព្យសម្បត្តិ កំណើត ពិការភាព ឬស្ថានភាពផ្សេងទៀតឡើយ។ អំណាចក្នុងគ្រាអាសន្ន គួរត្រូវបានប្រើក្នុងរង្វង់ ដែលចែងដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិ (IHRL) ដែលទទួលស្គាល់ថា រដ្ឋអាចត្រូវការអំណាចបន្ថែម ដើម្បីដោះស្រាយស្ថានការណ៍លើកលែងជាពិសេស។ អំណាចបែបនេះ គួរតែត្រូវបានកំណត់ពេលវេលា ហើយអនុវត្តជាបណ្ដោះអាសន្នតែប៉ុណ្ណោះ ក្នុងគោលបំណង ដើម្បីស្ដារស្ថានភាពមកសភាពធម្មតាវិញឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

នៅពេលដែលរដ្ឋមួយចំនួន ប្រកាន់យកវិធានការតឹងរឹង ដើម្បីការពារប្រជាពលរដ្ឋ ទាំងនេះមិនគួរត្រូវបានប្រើជាហេតុផល ដើម្បីផាត់ជនជាតិភាគតិចចេញ ដែលជាហេតុនាំឲ្យមានការកើនឡើងនូវការរើសអើង ហឹង្សា សន្ទរកហាបង្កការខឹងស្អប់ និងវិសមភាព។ ការបន្តផាត់ជនជាតិភាគតិចចេញក្នុងអំឡុងពេលនៃជំងឺរាតត្បាតនេះ រួមទាំងការស្អប់ខ្ពើមជនបរទេស ឬសុន្ទរកថាប្រកាន់ជាតិសាសន៍ ដែលជាប់ទាក់ទងនឹងជនជាតិភាគតិច ជាហេតុបណ្ដាលមកពីជំងឺកូវីដ-១៩ ជាដើមហេតុនៃជម្លោះ និងអសន្តិសុខ និងនាំឲ្យមានការរំលោភសិទ្ធិមនុស្សកាន់តែច្រើនថែមទៀត។

ច្បាប់សិទ្ធិមនុស្សអន្តរជាតិដាក់កាតព្វកិច្ចវិជ្ជមាន និងភារៈកិច្ចលើរដ្ឋ និងតួអង្គដទៃទៀត ដើម្បីពង្រឹងការប្រារព្ធភាពចម្រុះ។ វិបត្តិជំងឺកូវីដ-១៩ អាចបង្កើតជាឱកាស ដើម្បីពង្រឹងការរាប់បញ្ចូលអ្នកដែលប្រឈមនឹងការដែលត្រូវគេទុកចោល ក៏ដូចជា បង្កើនសាមគ្គីភាពសង្គម។ យើងជំរុញឲ្យមានវិធានការចំពោះកាតព្វកិច្ច និងឱកាសទាំងនេះ។

## ឧបសម្ព័ន្ធ៣៖ សេចក្តីណែនាំរបស់ការិយាល័យ OHCHR ស្តីពីជំងឺកូវីដ-១៩ និងជនជាតិដើមភាគតិច (មេសា ២០២០)

ការរាតត្បាតជាសាកលនៃជំងឺកូវីដ-១៩ មិនអាចត្រូវបានបំបែកចេញពីបញ្ហាប្រឈមខាងសិទ្ធិមនុស្សដែលជនជាតិដើមភាគតិចប្រឈមមុខនៅទូទាំងពិភពលោកបានឡើយ ដោយរួមបញ្ចូលទាំងអត្រាខ្ពស់នៃហានិភ័យសុខភាព និងតម្រូវការមិនស្មើគ្នាទាក់ទងនឹងការថែទាំសុខភាព កង្វះទឹកស្អាតប្រកបដោយសុវត្ថិភាព លំនៅឋានចង្អៀតណែន និងកង្វះប្រព័ន្ធលូ។ សិទ្ធិសុខភាពជនជាតិដើមភាគតិច មានហានិភ័យស្រាប់ហើយក្នុងជីវិភាពប្រចាំថ្ងៃ ឬ "ប្រក្រតី" ហើយភាពងាយរងគ្រោះរបស់ពួកគេកាន់តែធ្ងន់ធ្ងរក្នុងស្ថានភាពគ្រោះមហន្តរាយ ដែលបញ្ហាប្រឈមទាំងនេះ មិនទាន់ត្រូវបានដោះស្រាយនៅឡើយ។

ជនជាតិដើមភាគតិចស្ថិតក្នុងចំណោមជនងាយរងគ្រោះបំផុតពីជំងឺកូវីដ-១៩ ដោយសារមូលហេតុជាច្រើន រួមមាន៖

* សហគមន៍ជនជាតិដើមភាគតិចភាគច្រើនមានទីតាំងនៅតំបន់ដាច់ស្រយាល ជាញឹកញាប់ត្រូវបានទុកចោលដោយមានលទ្ធភាពតិចតួចក្នុងការទទួលបានការថែទាំសុខភាព ការគាំទ្រខាងវេជ្ជសាស្ត្រ និងព័ត៌មានដែលអាចទុកចិត្តបាន។ មនុស្សចាស់ និងមនុស្សដែលមានជំងឺរ៉ាំរ៉ៃ តម្រូវឲ្យមានការសង្គ្រោះបន្ទាន់ ជាពិសេស បញ្ហាផ្លូវដង្ហើមដែលត្រូវយកចិត្តទុកដាក់ខ្លាំងទៅលើតំបន់ទាំងនេះ ដែលជាកន្លែងពិបាករកសេវាថែទាំផ្នែកវេជ្ជសាស្ត្រ។

* ជនជាតិដើមភាគតិចងាយរងគ្រោះថ្នាក់ពីជំងឺរាតត្បាត។ ជំងឺឆ្លង ដូចជា ជំងឺគ្រុនឈាម និងជំងឺគ្រុនចាញ់បានបំផ្លាញសហគមន៍ជនជាតិដើមភាគតិចអស់ជាច្រើនទសវត្សមកហើយ។ ជនជាតិដើមភាគតិចជាច្រើន ធ្លាប់មានបទពិសោធន៍កាត់បន្ថយភាពស៊ាំដោយសារជំងឺ ដោយយល់ថាវាជាជំងឺធ្លាសាយធម្មតា។ ដូច្នេះ ជនជាតិដើមភាគតិច និងជាពិសេស ជនជាតិដើមភាគតិចដែលរស់នៅក្នុងភាពឯកោដោយស្ម័គ្រចិត្ត ឬទំនាក់ទំនងបឋម គឺងាយរងគ្រោះណាស់ទៅនឹងជំងឺកូវីដ-១៩ ដូចដែលពួកគេបានបង្ហាញភាពស៊ាំតិចតួចទៅនឹងជំងឺផ្លូវដង្ហើមកាលពីអតីតកាល។

* ពេលថ្មីៗនេះ មានការធ្លាក់ចុះនៃគុណភាពបរិស្ថាននៅក្នុងសហគមន៍ជនជាតិដើមភាគតិចជាច្រើន ដូចជាការបាត់បង់ជីវៈចម្រុះដោយការបំពុលបរិស្ថាន បានធ្វើឲ្យប៉ះពាល់ដល់គុណភាពម្ហូបអាហាររបស់ជនជាតិដើមភាគតិច កាត់បន្ថយនូវចំនួនត្រីសាច់ដែលពួកគេធ្លាប់រកបានកាលពីមុនមក។

* ការយល់ឃើញខុស និងព័ត៌មានមិនត្រឹមត្រូវ ក៏បណ្តាលឲ្យមានការរើសអើងជាតិសាសន៍នៅទូទាំងពិភពលោក ហើយជនជាតិដើមភាគតិច ក៏ជាគោលដៅនៃការរើសអើងទាំងនេះផងដែរ។

* នៅប្រទេសខ្លះ មានវិសមាមាត្រនៃការដាក់ពន្ធនាគារជនជាតិដើមភាគតិចផងដែរ។ អ្នកជាប់ពន្ធនាគារងាយនឹងរងគ្រោះខ្លាំងណាស់ចំពោះជំងឺកូវីដ-១៩ នេះ ជាពិសេស ជនជាតិដើមភាគតិច ដែលមានវ័យចាស់ជរា និងឬ អ្នកដែលមានបញ្ហាសុខភាព។

១. ជនជាតិដើមភាគតិច គួរតែត្រូវបានចាត់ទុកថាជាដៃគូមូលដ្ឋានក្នុងការដោះស្រាយបញ្ហារាតត្បាតរបស់មេរោគ។ រដ្ឋគួរពិចារណាចំពោះទស្សនៈរបស់ជនជាតិដើមភាគតិចទៅលើបញ្ហាសុខភាព ដែលត្រូវបានផ្សារភ្ជាប់ជាមួយនឹងការយល់ដឹងអំពីសិទ្ធិផ្សេងទៀត រួមទាំងសិទ្ធិក្នុងការធ្វើសេចក្តីសំរេចចិត្តខ្លួនឯង ការអភិវឌ្ឍ វប្បធម៌ ដីធ្លី ភាសា និងបរិស្ថា

នធម្មជាតិ។ ពួកគេគួរតែពិគ្រោះយោបល់ជាមួយជនជាតិដើមភាគតិច និងទទួលយកការឯកភាពរបស់ពួកគេតាមរយៈគោលការណ៍នៃការពិគ្រោះយោបល់ និងឯកភាពដោយសេរី ប្រាសចាកការបង្ខិតបង្ខំ (FPIC) នៅពេលធ្វើការសំរេចចិត្តដែលជះឥទ្ធិពលដោយផ្ទាល់ដល់ពួកគេ រួមទាំងការបង្ការ និងការទប់ស្កាត់ជំងឺ។

២. គួរតែផលិតជាភាសាជនជាតិដើមភាគតិចនូវព័ត៌មានត្រឹមត្រូវ និងទាន់ហេតុការណ៍អំពីការការពារ និងការថៃទាំ វិធីស្វែងរកជំនួយក្នុងករណីមានរោគសញ្ញា ហើយនិងកិច្ចការដែលបាននិងកំពុងធ្វើ ដើម្បីដោះស្រាយការរាតត្បាតតាមដែលអាចធ្វើទៅបាន។

៣. រដ្ឋត្រូវដាក់ចេញនូវវិធានការសម្រាប់ការគ្រប់គ្រងយ៉ាងតឹងរឹងចំពោះការចេញចូលរបស់បុគ្គលណាមួយ ចូលទៅកាន់ដែនដីរបស់ជនជាតិដើមភាគតិច រួមទាំងអ្នកជំនាញសុខភាព មន្ត្រីសាធារណៈ ភ្ញៀវទេសចរណ៍ និងស្ថាប័នដៃគូ។ ជនណាដែលចូលក្នុងទឹកដីរបស់ជនជាតិដើមភាគតិច គួរតែត្រូវបានធ្វើតេស្តរកមើលជំងឺកូវីដ-១៩ និងឆ្លងកាត់ការវាយតំលៃខាងវេជ្ជសាស្រ្តជាមុន។

៤. រដ្ឋត្រូវបង្កើតផែនការដើម្បីផ្តល់លទ្ធភាពទទួលបានការថៃទាំសុខភាព សមស្របតាមវប្បធម៌ប្រពៃណី ក្នុងគោលបំណងធ្វើសមាហរណកម្មរវាងឱសថទំនើប និងឱសថបុរាណ រួមទាំងការប្រើប្រាស់ឧបករណ៍ ការធ្វើតេស្ត និងការថៃទាំជាបន្ទាន់សម្រាប់ជនជាតិដើមភាគតិច។ លើសពីនេះទៀត ការទទួលបានស្បៀងអាហារនៅពេលចាំបាច់ គួរតែជាបញ្ហាអាទិភាព។ ជនជាតិដើមភាគតិច គួរត្រូវបានបញ្ចូលទៅក្នុងកញ្ចប់ជំនួយសេដ្ឋកិច្ច និងគ្រោះមហន្តរាយ។

៥. ជនជាតិដើមភាគតិចរស់នៅដាច់ដោយឡែកដោយស្ម័គ្រចិត្ត ឬទំនាក់ទំនងបឋម គួរតែត្រូវបានចែកជាក្រុមងាយរងគ្រោះពិសេស។ របាំងការពារអ្នកខាងក្រៅមិនឲ្យចូលទឹកដីរបស់ពលរដ្ឋទាំងនេះ គួរត្រូវបានអនុវត្តយ៉ាងតឹងរឹងដើម្បីជៀសវាងការប៉ះពាល់។ ក្នុងន័យនេះ រដ្ឋត្រូវពិភាក្សា និងធ្វើការរួមគ្នាជាមួយអ្នកដឹកនាំជនជាតិដើមភាគតិច ជាជាងសហគមន៍ដែលមានជនជាតិដើមភាគតិច ដែលស្ម័គ្រចិត្តរស់នៅដាច់ដោយឡែក ឬទំនាក់ទំនងបឋម ដើម្បីការពារពួកគេពីការរាតត្បាត។